ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ



# តំបន់ដាំដុះដំណាំស្វាយចន្ទី នៅកម្ពុជាឆ្នាំ២០២៤

ផលិតដោយៈ នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម

រាជធានីភ្នំពេញ ខែតុលា ឆ្នាំ២០២៤

# តំបន់ដាំដុះដំណាំស្វាយចន្ទីនៅកម្ពុជាឆ្នាំ២០២៤

ឯកសារនេះបោះពុម្ពក្នុងឆ្នាំ២០២៤ ដោយនាយកដ្ឋានគ្រប់គ្រងធនធាដីកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

អាសយដ្ឋាន៖ លេខ ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ

គាំទ្រដោយ៖ កម្មវិធី SilvaCarbon

ដៃគូសហការ៖

# មាតិកា


បញ្ជីអក្សរកាត់ ............ iv
បុព្វកថា ............ v
អារម្ភកថា ............ vii
សេចក្ដីថ្លែងអំណរគុណ ............ ix
ក្រុមការងារបច្ចេកទេស ............ xi
បញ្ជីឈ្មោះអ្នកចូលរួមសិក្ខាសាលាផ្ទៀងផ្ទាត់ផែនទីតំបន់ដាំដុះដំណាំស្វាយចន្ទីនៅប្រទេសកម្ពុជា ............ xiii

## ជំពូក ១
## ព័ត៌មានទូទៅ

១.១ សេចក្ដីផ្ដើម ............ ១
១.២ គោលបំណង ............ ៣
១.៣ លទ្ធផលរំពឹងទុក ............ ៣
១.៤ ភាពសមស្របនៃដីសម្រាប់ដំណាំស្វាយចន្ទីនៅកម្ពុជា ............ ៣

## ជំពូក ២
## វិធីសាស្ត្រផលិតផែនទីដំណាំ

២.១ បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI) ម៉ាស៊ីនស្វ័យសិក្សា (ML) និង ការសិក្សាស៊ីជម្រៅ (DL) ............ ៥
២.២ បណ្ដាយណឺរ៉ូន (NN) ............ ៥
២.៣ The Google cloud environment ............ ៦
២.៣.១ ដំណើរការអនុវត្ត ............ ៦
២.៤ ការរៀបចំទិន្នន័យបង្ហាត់ ............ ៧
២.៤.១ ការជ្រើសរើសតំបន់គោលដៅ ............ ៨
២.៤.២ ការរៀបចំប្លង់យកទិន្នន័យ ............ ៩
២.៤.៣ ការងារទីវាល ............ ១០
២.៤.៤ ការគូសវាសទិន្នន័យបង្ហាត់ ............ ១២
២.៤.៥ សម្ភារៈចុះទីវាល ............ ១៤
២.៤.៦ កម្មវិធីប្រើប្រាស់ ............ ១៥

**២.៥ ដំណើរការផលិតផែនទីដំណាំ ............ ១៦**
២.៥.១ ការបង្ហាត់គំរូ ............ ១៦
២.៥.២ ការផ្ទៀងផ្ទាត់ និងការប៉ាន់ស្មានផ្ទៃដី ............ ១៧

## ជំពូក ៣
## លទ្ធផលនៃការផលិតផែនទីដំណាំស្វាយចន្ទី

**៣.១ លទ្ធផលនៃការផលិតផែនទីស្វាយចន្ទីជាតិ ............ ១៩**

**៣.២ ការប៉ាន់ប្រមាណផ្ទៃដីដំណាំស្វាយចន្ទីតាមបណ្តាខេត្ត ............ ១៩**

## ជំពូក ៤
## សន្និដ្ឋាន

**សន្និដ្ឋាន ............ ២១**
**ឯកសារយោង ............ ២៧**

## ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១: ការបរិយាយចំណាត់ថ្នាក់គម្របដី ............ ២២
ឧបសម្ព័ន្ធ២: ការពន្យល់ពីទិន្នន័យទីវាលសំខាន់ៗ ............ ២៥
ឧបសម្ព័ន្ធ៣: អក្សរកាត់ជាអក្សរឡាតាំងឈ្មោះរាជធានី-ខេត្ត សម្រាប់ប្រើប្រាស់ក្នុងការរៀបចំទិន្នន័យនៅទីវាល ..... ២៥

## រូបភាព

រូបភាពទី១: ការប្រើប្រាស់ Google Cloud Environment សម្រាប់ដំណើរនិងវិភាគរូបភាពផ្កាយរណប ............ ៧

រូបភាពទី២: ការរៀបចំទិន្នន័យបង្ហាត់ ............ ៨

រូបភាពទី៣: ខេត្តគោលដៅទាំង១៩ ............ ៩

រូបភាពទី៤: ការរៀបចំប្លង់យកទិន្នន័យក្នុងកម្មវិធី QGIS ............ ១០

រូបភាពទី៥: ការគូសវាសទិន្នន័យបង្ហាត់ ............ ១២

រូបភាពទី៦: ទិន្នន័យគូសវាសរួចក្នុងប្លង់ ៤x៤គ.ម ក្នុងខេត្តគោលដៅចំនួន១៩ ............ ១៤

រូបភាពទី៧: ដ្រូនប្រើប្រាស់ដើម្បីប្រមូលទិន្នន័យ ............ ១៥

រូបភាពទី៨: កម្មវិធីនិងទិន្នន័យប្រើប្រាស់ ............ ១៥

រូបភាពទី៩: កម្មវិធី CarryMap ប្រើប្រាស់សម្រាប់ប្រមូលទិន្នន័យនៅទីវាល ............ ១៦

រូបភាពទី១០: តារាងលំហូរការបង្ហាត់គំរូ.......... ១៧

រូបភាពទី១១: ស្ថាបត្យកម្ម U-net សម្រាប់គំរូ CNNs .......... ១៧

រូបភាពទី១២: ផែនទីតំបន់ដាំដុះដំណាំស្វាយចន្ទីនៅប្រទេសកម្ពុជាឆ្នាំ ២០២៤ .......... ១៩

## តារាង

តារាងទី១: តារាងប្រមូលទិន្នន័យទីវាល .......... ១១

តារាងទី២: ចំណាត់ថ្នាក់គម្របដី .......... ១៣

តារាងទី៣: ចំនួនប្លង់សរុបក្នុងខេត្តគោលទាំង១៩ខេត្ត .......... ១៣

តារាងទី៤: ផ្ទៃដី និងបរិមាណផលប៉ាន់ស្មានដោយប្រើប្រាស់ទិន្នន័យផែនទីស្វាយចន្ទីជាតិក្នុងឆ្នាំ២០២៤ .......... ២០

# បញ្ជីអក្សរកាត់

| អក្សរកាត់ | ពាក្យពេញ | |
|---|---|---|
| AI | Artificial Intelligence | បញ្ញាសិប្បនិម្មិត |
| CI | Confidence Interval | គម្លាតជឿជាក់ |
| DALRM | Department of Agricultural Land Resources Management | នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម |
| DGIS | Department of Geospatial Information Service | នាយកដ្ឋានសេវាកម្មព័ត៌មានភូមិសាស្ត្រ |
| DL | Deep Learning | បច្ចេកទេសសិក្សាស៊ីជម្រៅដោយម៉ាស៊ីនកុំព្យូទ័រ |
| GDA | GDA General Directorate of Agriculture | អគ្គនាយកដ្ឋានកសិកម្ម |
| GDP | Gross Domestic Product | ផលិតផលក្នុងស្រុកសរុប |
| GIS | Geographic Information System | ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ |
| IAEA | International Atomic Energy Agency | ទីភ្នាក់ងារថាមពលបរិមាណូអន្តរជាតិ |
| LULC | Land Use Land Cover | ការប្រើប្រាស់ដី គម្របដី |
| MAFF | Ministry of Agriculture Forestry and Fisheries | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ML | Machine Learning | ម៉ាស៊ីនស្វ័យសិក្សា |
| MoE | Ministry of Environment | ក្រសួងបរិស្ថាន |
| NN | Neural network | បណ្តាញណឺរ៉ូន |
| PDAFFs | Provincial Department of Agriculture, Forestry and Fisheries | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត |
| RS | Remote Sensing | បច្ចេកវិទ្យាផ្តាយរណប |

# បុព្វកថា

ដំណាំស្វាយចន្ទី ជាដំណាំឧស្សាហកម្មមានសក្តានុពលខ្ពស់របស់ប្រទេសកម្ពុជា និងមានកេរ្តិ៍ឈ្មោះល្បី ជាពិសេសមានការទទួលស្គាល់លើទីផ្សារអំពីគុណភាព រសជាតិ ទំហំគ្រាប់ និងពូជប្រពៃណី។ ដំណាំស្វាយចន្ទីងាយស្រួលដាំដុះ ត្រូវការទឹកតិចតួចសម្រាប់ការលូតលាស់ ធន់នឹងភាពរាំងស្ងួត សមស្រមទៅនឹងអាកាសធាតុ និងសណ្ឋានដីនៅប្រទេសកម្ពុជា។ ខេត្តដែលបានដាំដុះដំណាំស្វាយចន្ទីច្រើនជាងគេ គឺមានខេត្តកំពង់ធំ ក្រចេះ រតនគិរី កំពង់ចាម ស្ទឹងត្រែង ត្បូងឃ្មុំ សៀមរាប ព្រះវិហារ ឧត្តរមានជ័យ និងមណ្ឌលគិរី។ ប្រទេសកម្ពុជាមានលក្ខខណ្ឌដីសមស្របខ្ពស់ដែលមានសក្តានុពលសម្រាប់ដាំដុះដំណាំស្វាយចន្ទីប្រមាណជាង ១,២៤លានហិកតា ហើយបច្ចុប្បន្ននេះ ផ្ទៃដីដែលបានដំណាំស្វាយចន្ទីសរុបមានប្រមាណ ៥៨០ ១១៧ ហិកតា ក្នុងនោះ ខេត្តកំពង់ធំមានផ្ទៃដីដាំដុះច្រើនជាងគេសរុបមានចំនួនប្រមាណជា ១៤៧ ៧០០ ហិកតា។ ប្រទេសកម្ពុជានាំចេញគ្រាប់ស្វាយចន្ទីឆៅប្រមាណជាង ៩០ ភាគរយនៃបរិមាណនាំចេញគ្រាប់ស្វាយចន្ទីសរុបរបស់ខ្លួន។

ក្នុងឆ្នាំ២០២៣ រាជរដ្ឋាភិបាលកម្ពុជានៃព្រះរាជាណាចក្រកម្ពុជាបានដាក់ចេញនូវគោលនយោបាយជាតិ ស្តីពីស្វាយចន្ទី ឆ្នាំ២០២២-២០២៧ ដែលមានគោលបំណងធ្វើឱ្យកម្ពុជាក្លាយជាប្រទេសផលិត និងផ្គត់ផ្គង់ផលិតផលស្វាយចន្ទីដ៏សំខាន់មួយប្រកបដោយភាពប្រកួតប្រជែងទាំងផ្នែកគុណភាព និងរសជាតិសម្រាប់បម្រើទីផ្សារក្នុងស្រុក តំបន់ និងពិភពលោក ឈានទៅសម្រេចចក្ខុវិស័យប្រែក្លាយប្រទេសកម្ពុជាជាអធិរាជស្វាយចន្ទី។

ក្នុងឆ្នាំ២០២៤ នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្មនៃអគ្គនាយកដ្ឋានកសិកម្មបានផលិតផែនទីតំបន់ដាំដុះដំណាំស្វាយចន្ទីនៅទូទាំងប្រទេសកម្ពុជា បានប្រកបដោយជោគជ័យដោយប្រើប្រាស់បច្ចេកវិទ្យាម៉ាស៊ីនស្វ័យសិក្សា (Machine Learning) បញ្ញាសិប្បនិម្មិត (AI) និងម៉ូដែល CNNs (Convolutional Neural Networks) ដែលជាស្នាដៃដំបូងបំផុតនៃការផលិតផែនទីតំបន់ដាំដុះដំណាំដោយប្រើបច្ចេកវិទ្យាទាន់សម័យបែបនេះរបស់កម្ពុជា។ នេះគឺជាសមិទ្ធផលដ៏សំខាន់មួយក្នុងការចូលរួមចំណែកអនុវត្តគោលនយោបាយជាតិស្តីពីស្វាយចន្ទីរបស់រាជរដ្ឋាភិបាលកម្ពុជា។ សមិទ្ធផលនេះ ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ផ្លូវការនៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៤ ក្រោមអធិបតីភាព **ឯកឧត្តម តួច ប៊ុនហួរ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ផលិតផលនេះផ្តល់នូវអត្ថប្រយោជន៍ច្រើនដូចជា ទិន្នន័យត្រឹមត្រូវសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្រ ការវិភាគសក្តានុពលផលិតកម្ម ការវិភាគខ្សែច្រវ៉ាក់ផលិតកម្ម និងការវិភាគទីផ្សារ ព្រមទាំងជួយដល់ការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកសិកម្មលើសុខភាពដី ប្រព័ន្ធកសិអេកូឡូស៊ី និងការជួយជំរុញឱ្យមានការអភិវឌ្ឍធនធានដីកសិកម្មប្រកបដោយនិរន្តរភាព ប្រសិទ្ធភាពសេដ្ឋកិច្ច និងបរិស្ថាន។ ម៉្យាងទៀត ការផលិតផែនទីប្រើប្រាស់ដីកសិកម្មឱ្យបានទូលំទូលាយជួយបង្កើនប្រសិទ្ធភាពនៃការសិក្សាតាមដានស្ថានភាពបម្រែបម្រួលការប្រើប្រាស់ដីកសិកម្ម។

អគ្គនាយកដ្ឋានកសិកម្ម ពិតជាមានក្តីសោមនស្សរីករាយប្រកបដោយមោទនភាពចំពោះសមិទ្ធផលដ៏មានសារៈសំខាន់នេះ និងសូមកោតសរសើរយ៉ាងស្មោះចំពោះថ្នាក់ដឹកនាំ និងមន្ត្រីនៃនាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម ដែលបានខិតខំប្រឹងប្រែងបំពេញការងារ ជំនះគ្រប់ឧបសគ្គ មានការអត់ធ្មត់ និងការប្តេជ្ញាចិត្តយ៉ាងមុតមាំលើការដឹកនាំ និង

ការអនុវត្តការងារទាំងផ្នែកសម្របសម្រួល ផ្នែកទិដ្ឋភាពបច្ចេកទេស ព្រមទាំងមានកិច្ចសហការល្អជាមួយដៃគូអន្តរជាតិ និងអ្នកពាក់ព័ន្ធនានារហូតទទួលបានជោគជ័យក្នុងការផលិតផែនទីតំបន់ដាំដុះដំណាំស្វាយចន្ទីរបស់កម្ពុជា។

ក្នុងនាមអគ្គនាយកដ្ឋានកសិកម្ម ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកម្មវិធី SilvaCarbon របស់ក្រសួងកសិកម្មសហរដ្ឋអាមេរិក អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO) ទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិ (IAEA) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP-SCALA) និងSpatial Informatics Group (SIG-GIS) ចំពោះការគាំទ្រជាបន្តបន្ទាប់លើផ្នែកហិរញ្ញវត្ថុ បច្ចេកទេស និងការកសាងសមត្ថភាពស្ថាប័នដើម្បីអនុវត្តសកម្មភាពការងារដែលសម្រេចបានសមិទ្ធផលដ៏មានសារៈសំខាន់នេះ។ ជាមួយគ្នានេះ ខ្ញុំក៏សូមអរគុណចំពោះកិច្ចសហការ និងការគាំទ្រយ៉ាងសកម្មពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនៃរាជធានី-ខេត្តទាំង២៥ និងក្រុមការងារបច្ចេកទេសរបស់ក្រសួងបរិស្ថានផងដែរ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ **ឯកឧត្តម ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលតែងតែយកចិត្តទុកដាក់គាំទ្រអស់ពីកម្លាំងកាយចិត្តលើការសិក្សាអំពីការផលិតផែនទីតំបន់ដាំដុះដំណាំកសិកម្មដោយប្រើប្រាស់បច្ចេកវិទ្យាផ្កាយរណប។ សូមគ្រប់ភាគីពាក់ព័ន្ធទាំងអស់ប្រើប្រាស់ និងចូលរួមផ្សព្វផ្សាយឯកសារស្តីពីតំបន់ដាំដុះដំណាំស្វាយចន្ទីនៅប្រទេសកម្ពុជាដ៏មានសារៈសំខាន់នេះឱ្យបានទូលំទូលាយ ប្រកបដោយភាពជឿជាក់។ អគ្គនាយកដ្ឋានកសិកម្មនៅតែបន្តសិក្សា និងវាយតម្លៃបម្រែបម្រួលការប្រើប្រាស់ដីដាំដុះដំណាំស្វាយចន្ទី និងធ្វើបច្ចុប្បន្នភាពតាមពេលវាកំណត់។

ថ្ងៃចន្ទ ៤រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៤
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក**
**នៃអគ្គនាយកដ្ឋានកសិកម្ម**

**ឯកឧត្តមបណ្ឌិត ងិន ឆាយ**

# អារម្ភកថា

នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម គឺជាសេនាធិការជំនាញមួយរបស់អគ្គនាយកដ្ឋានកសិកម្មដែលមានបេសកកម្មក្នុងការគ្រប់គ្រងការប្រើប្រាស់ធនធានដីកសិកម្មប្រកបដោយនិរន្តរភាពក្នុងប្រទេសកម្ពុជា តាមរយៈការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍បច្ចេកទេសកែលម្អដី ការអភិរក្សដីកសិកម្ម ការទប់ស្កាត់បញ្ហានៃការធ្លាក់ចុះគុណភាពដី ការកំណត់តំបន់ដាំដុះកសិកម្ម ការអង្កេតនិងវាយតម្លៃធនធានដី ការគ្រប់គ្រងដីកសិកម្ម ការសិក្សាពីតម្រូវការទឹករបស់ដំណាំ និងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុក្នុងផលិតកម្មដំណាំ។

ការផលិតផែនទីតំបន់ដាំដុះដំណាំកសិកម្ម គឺជាសកម្មភាពមួយដើម្បីចូលរួមអនុវត្តសកម្មភាពអាទិភាពរបស់គោលនយោបាយជាតិស្តីពីស្វាយចន្ទីឆ្នាំ២០២២-២០២៧ ដែលរាជរដ្ឋាភិបាលកម្ពុជាបានអនុម័តក្នុងឆ្នាំ២០២៣។ នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្មបានអភិវឌ្ឍសមត្ថភាពលើការប្រើប្រាស់បច្ចេកវិទ្យាម៉ាស៊ីនស្វ័យសិក្សា ដែលជាវិធីសាស្ត្រថ្មីមកប្រើប្រាស់ដើម្បីផលិតផែនទីតំបន់ដាំដុះដំណាំស្វាយចន្ទីនៅទូទាំងប្រទេសកម្ពុជាតាមរយៈការពង្រឹងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍អន្តរជាតិ និងស្ថាប័នជាតិ។ ក្នុងការប្រើប្រាស់បច្ចេកវិទ្យាម៉ាស៊ីនស្វ័យសិក្សាដើម្បីផលិតផែនទីតំបន់ដាំដុះដំណាំស្វាយចន្ទី យើងបានបង្កើតទិន្នន័យទីវាលចំនួន ១៩៥ប្លង់ ដែលមួយប្លង់មានទំហំ ៤x៤គ.ម (មានផ្ទៃក្រឡា ១៦ គីឡូម៉ែត្រការ៉េ) ក្នុងខេត្តគោលដៅចំនួន១៩។ ក្នុងប្លង់នីមួយៗត្រូវបានគូសជាប៉ូលីហ្គោន (Digitizing)ដែលតំណាងឱ្យដំណាំផ្សេងៗ ដែលក្នុង១៩៥ប្លង់ មានចម្ការដំណាំស្វាយចន្ទីសរុបចំនួន ១០ ១៤៧ ប៉ូលីហ្គោន។ ប៉ូលីហ្គោនស្វាយចន្ទីត្រូវបានប្រើប្រាស់ដើម្បីបង្ហាត់កម្មវិធីម៉ាស៊ីនស្វ័យសិក្សាតាមរយៈការប្រើប្រាស់គំរូបណ្តាញណឺរ៉ូន (CNNs) និងកម្មវិធី TensorFlow រួមបញ្ចូលជាមួយទិន្នន័យរូបភាពផ្កាយរណប PlanetScope (NICFI)។ លទ្ធផលផែនទីបឋមត្រូវបានទាញយកមកប្រើប្រាស់ និងផ្ទៀងផ្ទាត់ដោយការប្រើប្រាស់ Google Earth Engine (GEE)។ លទ្ធផលផែនទីចុងក្រោយត្រូវបានផលិតដោយបានឆ្លងកាត់ការផ្ទៀងផ្ទាត់ជាក់ស្តែងនៅទីវាល សិក្ខាសាលាផ្ទៀងផ្ទាត់ជាមួយភាគីពាក់ព័ន្ធ និងកិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំគោលនយោបាយដើម្បីពិនិត្យ និងសម្រេចលើលទ្ធផលផែនទី និងផ្ទៃដីដាំដុះដំណាំស្វាយចន្ទីតាមបណ្តារាជធានី-ខេត្តទាំង២៥។

ក្នុងឆ្នាំ២០២៤ ផែនទី និងសៀវភៅស្តីពីតំបន់ដាំដុះដំណាំស្វាយចន្ទីនៅកម្ពុជាត្រូវបានបោះពុម្ពដោយជោគជ័យ។ ឯកសារនេះផ្តល់នូវបច្ចុប្បន្នភាពនៃព័ត៌មានអំពី ផ្ទៃដីដាំដុះដំណាំស្វាយចន្ទីតាមខេត្តនីមួយៗ ការប៉ាន់ស្មានបរិមាណផលតាមខេត្តនិងទូទាំងប្រទេស និងផែនទីតំបន់ដាំដុះដំណាំស្វាយចន្ទីសំខាន់ៗទូទាំងប្រទេស។ លទ្ធផលនៃការសិក្សានេះបានបង្ហាញថា កម្ពុជាមានផ្ទៃដីដាំដុះដំណាំស្វាយចន្ទីសរុបចំនួន ៥៨០ ១១៧ ហិកតា និងអាចមានសក្តានុពលផលិតកម្មប្រមាណជា ៨១៦ ៤៥៩ តោនក្នុងមួយឆ្នាំ ហើយផ្អែកលើតួលេខនេះ កម្ពុជាឈរក្នុងចំណោមប្រទេសចំនួន៣ដែលផលិតស្វាយចន្ទីច្រើនជាងគេនៅលើពិភពលោក។

ការផលិតបានឯកសារដ៏មានសារៈសំខាន់នេះ អាចសម្រេចទៅបានដោយសារមានការគាំទ្រ ការតម្រង់ទិសនិងការណែនាំយ៉ាងយកចិត្តទុកដាក់បំផុតពីសំណាក់ **ឯកឧត្តម ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ឯកឧត្តម តូច ប៊ុនហួរ** រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយនឹងការដឹកនាំ

ផ្ទាល់ប្រកបដោយភាពឈ្លាសវៃ អត់ធ្មត់ និងម៉ឺងម៉ាត់របស់ **ឯកឧត្តមបណ្ឌិត ខិន ឆាយ** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម។

ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃនាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះថ្នាក់ដឹកនាំគ្រប់លំដាប់ថ្នាក់នៃអគ្គនាយកដ្ឋានកសិកម្មចំពោះការគាំទ្រ ប្រកបដោយឆន្ទៈមោះមុត ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់របស់នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្មជាពិសេសការិយាល័យកំណត់តំបន់ដាំដុះកសិកម្ម ដែលបានខិតខំប្រឹងប្រែងអស់ពីសមត្ថភាពប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការបំពេញការងារឱ្យសម្រេចបានជោគជ័យ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ កម្មវិធី SilvaCarbon នៃក្រសួងកសិកម្មសហរដ្ឋអាមេរិក ចំពោះការគាំទ្រផ្នែកហិរញ្ញវត្ថុនិងបច្ចេកទេស អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ(FAO) ទីភ្នាក់ងារថាមពលបរមាណូអន្តរជាតិ (IAEA) Spatial Informatics Group (SIG) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP-SCALA) ចំពោះការគាំទ្រផ្នែកបច្ចេកទេសនិងការកសាងសមត្ថភាពស្ថាប័ន ក្រុមការងារក្រសួងបរិស្ថានចំពោះកិច្ចសហការបច្ចេកទេស ហើយក៏សូមអរគុណដល់ថ្នាក់ដឹកនាំនិងមន្ត្រីនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំង២៥ ចំពោះកិច្ចសហការចូលរួមគាំទ្រយ៉ាងសកម្មលើការផ្ទៀងផ្ទាត់ទិន្នន័យដែលធ្វើឱ្យសម្រេចបាននូវសមិទ្ធផលដ៏មានសារៈសំខាន់នេះប្រកបដោយភាពជឿជាក់។

ថ្ងៃចន្ទ ៤រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៤
**ប្រធាននាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម**
**នៃអគ្គនាយកដ្ឋានកសិកម្ម**

**បណ្ឌិត សេង វ៉ាង**

# សេចក្ដីថ្លែងអំណរគុណ

យើងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ **ឯកឧត្តម ឌិត ទីណា** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានយកអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី ក្នុងការគាំទ្រ ដឹកនាំ និងតម្រង់ទិសដល់ការសិក្សាដើម្បីអភិវឌ្ឍតំបន់ដាំដុះដំណាំស្វាយចន្ទីនៅកម្ពុជាឱ្យទទួលបានជោគជ័យ។ ជាមួយនេះយើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយកដ្ឋានកសិកម្ម មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត និងដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ ចំពោះការគាំទ្រ និងកិច្ចសហការក្នុងការសិក្សា និងផលិតផែនទីតំបន់ដាំដុះដំណាំស្វាយចន្ទីនៅកម្ពុជា ដូចមានរាយនាមខាងក្រោម៖

| | |
|---|---|
| ១. **ឯកឧត្តម តូច ម៉ុនហួរ** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ២. **ឯកឧត្តម សុខ  វិសាល** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៣. **ឯកឧត្តម ឈុំ ឆុនលី** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៤. **ឯកឧត្តម ប៉ក់ សម័យ សុនីតិ** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ៥. **ឯកឧត្តមបណ្ឌិត ខិន ឆាយ** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកសិកម្ម |
| ៦. **លោកបណ្ឌិត ម៉ាក់ សឿន** | អគ្គនាយករង នៃអគ្គនាយកដ្ឋានកសិកម្ម |
| ៧. **លោក ហូ ពុទ្ធា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានកសិកម្ម |
| ៨. **លោក ប្រាក់ ជាតិថូ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានកសិកម្ម |
| ៩. **លោកស្រី ស៊ិន សោភ័ណ** | អគ្គនាយិការង នៃអគ្គនាយកដ្ឋានកសិកម្ម |
| ១០. **លោកស្រី គិត វិសិដ្ឋកញ្ញា** | អគ្គនាយិការង នៃអគ្គនាយកដ្ឋានកសិកម្ម |
| ១១. **លោកបណ្ឌិត ជូ ជ័យឆិរិទ្ធ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានកសិកម្ម |
| ១២. **លោកបណ្ឌិត នី ឧុទ្ធី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានកសិកម្ម |
| ១៣. **លោកបណ្ឌិត យិន ច័ន្ទសុធី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានកសិកម្ម |
| ១៤. **លោកបណ្ឌិត យន ទ្រី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានកសិកម្ម |
| ១៥. **លោក ធីវ វណ្ណធីរ** | ប្រធាននាយកដ្ឋានដំណាំឧស្សាហកម្ម |
| ១៦. **លោក ស៊ីន វិចិត្រ** | ប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និង សហប្រតិបត្តការអន្តរជាតិ |
| ១៧. **លោកបណ្ឌិត គង់ គា** | ប្រធាននាយកដ្ឋានដំណាំស្រូវ |
| ១៨. **លោកបណ្ឌិត កែ មុន្នីវុធ** | ប្រធាននាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ |
| ១៩. **លោក សេង ឧុយ** | ប្រធាននាយកដ្ឋានវិស្វកម្មកសិកម្ម |
| ២០. **លោក ជា សាំងឌូណា** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម |
| ២១. **លោក អោម ពេជ្រ** | ប្រធាននាយដ្ឋានពូជដំណាំ |
| ២២. **លោក សាយ តុម** | អនុប្រធានទទួលបន្ទុករួមនាយកដ្ឋានសាកវប្បកម្ម និងដំណាំរួមផ្សំ |
| ២៣. **លោក ហុក សៀង** | អនុប្រធានទទួលបន្ទុករួមមន្ទីរពិសោធន៍ជាតិកសិកម្ម |
| ២៤. **Dr. Marija Kono** | Southeast Asia Coordinator, USDA Forest Service |

២៥. **Dr. Ate Poortinga** Senior Scientist and Google Earth Engine Specialist SERVIR Southeast Asia

២៦. **Dr. Andrea McMahon** Senior Scientist, Environmental Mapping and Natural Hazards

២៧. **Dr. Andréa Puzzi Nicolau** Geospatial Data Scientist, Environmental Mapping

២៨. **Dr. Lee Kheng Heng** Former Technical Officer, International Atomic Energy Agency (IAEA)

២៩. **Dr. Hami Said Ahmed** Technical Officer, International Atomic Energy Agency (IAEA)

៣០. **សមាជិក សមាជិកា នៃក្រុមការងារបច្ចេកទេសសិក្សាស្រាវជ្រាវ និងផលិតផែនទីតំបន់ជំងុះដំណាំស្វាយចន្ទីនៅកម្ពុជា**

៣១. **ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទាំង២៥ រាជធានី-ខេត្ត**

## ក្រុមការងារបច្ចេកទេស
## សិក្សាស្រាវជ្រាវ និងផលិតផែនទីតំបន់ដាំដុះដំណាំស្វាយចន្ទីនៅកម្ពុជា

| | |
|---|---|
| ១. **លោកបណ្ឌិត សេង វ៉ាង** | ប្រធាននាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម |
| ២. **លោក អឿន ពិសិដ្ឋ** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម |
| ៣. **លោក អំ តិរម្យ** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម |
| ៤. **លោកស្រី ទុយ សុខខេង** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម |
| ៥. **លោក ឆិល ឆេន** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម |
| ៦. **លោក កន កុម្ភៈ** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម |
| ៧. **លោក គី ឈិន** | ប្រធានការិយាល័យកំណត់តំបន់ដាំដុះកសិកម្ម |
| ៨. **លោកស្រី ម៉ាន់ ម៉ារ៉ា** | ប្រធានការិយាល័យរដ្ឋបាល ផែនការ គណនេយ្យ និងសហប្រតិបត្តិការអន្តរជាតិ |
| ៩. **លោក ទឹម ធុន** | ប្រធានការិយាល័យអង្កេត និងចាត់ថ្នាក់ដីកសិកម្ម |
| ១០. **លោក កែប ប៉ុច** | ប្រធានការិយាល័យកែលម្អដីកសិកម្ម |
| ១១. **លោក គន់ ច័ន្ទតារ៉ា** | ប្រធានការិយាល័យសិក្សាស្រាវជ្រាវតម្រូវការទឹក និងបម្រែបម្រួលអាកាសធាតុ |
| ១២. **លោក ប៊ុន ច័ន្ទលីដា** | ប្រធានការិយាល័យគ្រប់គ្រងដីកសិកម្ម |
| ១៣. **លោក ព្រុំ ប៊ូរ៉ា** | អនុប្រធានការិយាល័យកំណត់តំបន់ដាំដុះកសិកម្ម |
| ១៤. **លោក វាសនា ឆៃយ៉ា** | អនុប្រធានការិយាល័យកំណត់តំបន់ដាំដុះកសិកម្ម |
| ១៥. **លោក សៃ សុខលាប** | មន្ត្រីការិយាល័យកំណត់តំបន់ដាំដុះកសិកម្ម |
| ១៦. **លោក កែវ និមល** | មន្ត្រីការិយាល័យកំណត់តំបន់ដាំដុះកសិកម្ម |
| ១៧. **លោក មុន សុភ័ណ** | មន្ត្រីការិយាល័យកំណត់តំបន់ដាំដុះកសិកម្ម |
| ១៨. **លោក នួន សារឿន** | មន្ត្រីការិយាល័យកំណត់តំបន់ដាំដុះកសិកម្ម |
| ១៩. **លោក កង សុជាតិ** | មន្ត្រីការិយាល័យកំណត់តំបន់ដាំដុះកសិកម្ម |
| ២០. **លោក សុខ សំអឿន** | មន្ត្រីការិយាល័យអង្កេត និងចាត់ថ្នាក់ដីកសិកម្ម |
| ២១. **លោក ខាត់ ពិសិដ្ឋ** | មន្ត្រីការិយាល័យអង្កេត និងចាត់ថ្នាក់ដីកសិកម្ម |
| ២២. **លោកស្រី ហួត ណាបូរី** | ប្រធានការិយាល័យវាយតម្លៃធនធានគម្របព្រៃឈើ និងសន្និធិកាបូន |
| ២៣. **លោក ម៉េញ យីដូវ៉េង** | អនុប្រធានការិយាល័យវាយតម្លៃធនធានគម្របព្រៃឈើ និងសន្និធិកាបូន |
| ២៤. **លោកបណ្ឌិត សូ ថន** | ទីប្រឹក្សាបច្ចេកទេសកសិកម្ម ព្រៃឈើ និងការប្រើប្រាស់ដី អង្គការស្បៀង និងកសិកម្ម នៃសហប្រជាជាតិ |
| ២៥. **លោកស្រី សារ សុគីរ៉ា** | អ្នកជំនាញការត្រួតពិនិត្យព្រៃឈើសម្រាប់តំបន់អាស៊ី នៃកម្មវិធី SilvaCarbon |

| | |
|---|---|
| ២៦. **Dr. Marija Kono** | Southeast Asia Coordinator, USDA Forest Service |
| ២៧. **Dr. Ate Poortinga** | Senior Scientist and Google Earth Engine Specialist SERVIR Southeast Asia |
| ២៨. **Dr. Andrea McMahon** | Senior Scientist, Environmental Mapping and Natural Hazards |
| ២៩. **Dr. Andréa Puzzi Nicolau** | Geospatial Data Scientist, Environmental Mapping |
| ៣០. **Dr. Lee Kheng Heng** | Former Technical Officer, International Atomic Energy Agency (IAEA) |
| ៣១. **Dr. Hami Said Ahmed** | Technical Officer, International Atomic Energy Agency (IAEA) |
| ៣២. **Dr. Jamil Mahmood** | Project Specialist - MRV United Nations Development Programme (UNDP) |

## បញ្ជីឈ្មោះអ្នកចូលរួម
## សិក្ខាសាលាផ្ទៀងផ្ទាត់ផែនទីតំបន់ដាំដុះដំណាំស្វាយចន្ទីនៅប្រទេសកម្ពុជា

| | |
|---|---|
| ១. លោក ចិន សត្យា | អនុប្រធានការិយាល័យ នៃនាយកដ្ឋានដំណាំឧស្សាហកម្ម |
| ២. លោក ស៊ុ ភារ៉ូ | មន្ត្រីការិយាល័យ នៃនាយកដ្ឋានរដ្ឋបាល ផែនការ គណនេយ្យ និង សហប្រតិបត្តការអន្តរជាតិ |
| ៣. លោកស្រី ស៊ឹម ព្រហស្បតិ៍ | ប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តបន្ទាយមានជ័យ |
| ៤. លោកស្រី ធឿក សុផានី | អនុប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តបន្ទាយមានជ័យ |
| ៥. លោក ខាត់ បូរិន | ប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តបាត់ដំបង |
| ៦. លោក ព្រំ វីក | អនុប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តបាត់ដំបង |
| ៧. លោក ហេង សិទ្ធិ | មន្ត្រីការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តបាត់ដំបង |
| ៨. លោក កាតំម សុវណ្ណារ៉ណ្ណ | អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ចាម |
| ៩. លោក មាន ជ័យ | មន្ត្រីការិយាល័យនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ចាម |
| ១០. លោក អែម វិសុទ្ធ | មន្ត្រីការិយាល័យនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ចាម |
| ១១. លោក មៀច ភារិទ្ធ | អនុប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ឆ្នាំង |
| ១២. កញ្ញា ផេង សុធីរ | អនុប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ឆ្នាំង |
| ១៣. លោក វង កុសល | មន្ត្រីការិយាល័យនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ឆ្នាំង |
| ១៤. លោក តុប សុភារៈ | ប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ |
| ១៥. កញ្ញា គិន ចិ | អនុប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ |
| ១៦. លោក សឿន សាន់ដា | អនុប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ស្ពឺ |
| ១៧. លោក ឈ បៀងគង់ | អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ធំ |
| ១៨. លោក ហ៊ុង សេងហាក់ | ប្រធានការិយាល័យនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ធំ |
| ១៩. លោក ប៉ូវ កុល | អនុប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ធំ |
| ២០. លោក សំ សុវណ្ណា | អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពត |

២១. លោក ជួប សុខ — មន្ត្រីការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពត
២២. លោកស្រី សំ មាលា — មន្ត្រីការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពត
២៣. លោក ឡុង សុខុន — មន្ត្រីការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកណ្ដាល

២៤. លោក អ៊ួង សុខសាន្ត — មន្ត្រីការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកណ្ដាល
២៥. លោកស្រី អែម សុធារ៉ា — ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកោះកុង
២៦. លោក សុខ សំអាត — អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកោះកុង
២៧. កញ្ញា ផាន់ សម្ផស្ស — ប្រធានការិយាល័យនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកោះកុង
២៨. លោក ម៉ៅ វិចិត្រ — អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តក្រចេះ
២៩. លោក សំ សំអាង — ប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តក្រចេះ
៣០. លោក អ៊ឹង យូទី — អនុប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តក្រចេះ
៣១. លោក សុង យាង — ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តមណ្ឌលគិរី
៣២. លោក សេង សៅ — ប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តមណ្ឌលគិរី
៣៣. លោក ហួត ដារីត — មន្ត្រីការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តមណ្ឌលគិរី
៣៤. លោក ស្រ៊ុន បូរិន្ទ — អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រះវិហារ
៣៥. លោក ឌី រស្មី — ប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រះវិហារ
៣៦. លោក លន់ ពល — មន្ត្រីការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រះវិហារ
៣៧. លោក សំ សារុន — អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រៃវែង
៣៨. លោក ប៊ុន សាខន — ប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រៃវែង
៣៩. លោកស្រី សាក់ សុខុម — អនុប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រៃវែង
៤០. លោក ហ៊ន់ សុវណ្ណ — អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តពោធិ៍សាត់
៤១. លោក មាស សេត — ប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តពោធិ៍សាត់
៤២. លោក ហ៊ៅ ចាន់ដារ៉ា — ប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តពោធិ៍សាត់
៤៣. លោក ញឹម គីមជាង — អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តរតនគិរី
៤៤. លោក សែម រឿន — ប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តរតនគិរី

| | |
|---|---|
| ៤៥. លោក ថន ណារុន | ប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តរតនគិរី |
| ៤៦. លោកស្រី សរ វីណោ | អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តសៀមរាប |
| ៤៧. លោក គង់ សុជា | ប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តសៀមរាប |
| ៤៨. លោក ជា សុភៈមករា | អនុប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តសៀមរាប |
| ៤៩. លោក អាត ផល្លី | ប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រះសីហនុ |
| ៥០. លោក សុខ រិទ្ធី | ប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រះសីហនុ |
| ៥១. លោក សុខ ពិសិដ្ឋ | មន្ត្រីការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រះសីហនុ |
| ៥២. លោក ផន ថុងលី | អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តស្ទឹងត្រែង |
| ៥៣. លោក តាំង ជីផេង | ប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តស្ទឹងត្រែង |
| ៥៤. លោក ង៉ា វុទ្ធី | មន្ត្រីការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តស្ទឹងត្រែង |
| ៥៥. លោក សុខ សុទ្ធាវុធ | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តស្វាយរៀង |
| ៥៦. លោក សុខ ចាន់ថន | ប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តស្វាយរៀង |
| ៥៧. លោក សុខ សំណាង | មន្ត្រីការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តស្វាយរៀង |
| ៥៨. លោក សុខ ចាន់សុផល | អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តតាកែវ |
| ៥៩. លោក សេង ម៉េង | ប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តតាកែវ |
| ៦០. លោក ឈន សារិត | អនុប្រធានការិយាល័យនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តតាកែវ |
| ៦១. លោក ឡឹក រ័ត្ន | អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តឧត្តរមានជ័យ |
| ៦២. លោក ហៃ ហ៊ាន់ | ប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តឧត្តរមានជ័យ |
| ៦៣. លោក សេន បូរ៉េន | អនុប្រធានការិយាល័យ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តឧត្តរមានជ័យ |
| ៦៤. លោក ចឹង បូរិន | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកែប |
| ៦៥. លោកស្រី ផាន់ ចិន្តា | អនុប្រធានការិយាល័យនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកែប |

| | |
|---|---|
| ៦៦. **លោកស្រី យ៉ូង សុវណ្ណារី** | អនុប្រធានការិយាល័យនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកែប |
| ៦៧. **លោក អ៊ីម សុភឿន** | អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តប៉ៃលិន |
| ៦៨. **លោក បុល ប៊ុន** | ប្រធានការិយាល័យនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តប៉ៃលិន |
| ៦៩. **លោក សាយ សួនភូមិរិរៈ** | មន្ត្រីកិច្ចសន្យា នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តប៉ៃលិន |
| ៧០. **លោក ហេង ពិសិដ្ឋ** | ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តត្បូងឃ្មុំ |
| ៧១. **លោក ដុក សារឿន** | ប្រធានការិយាល័យនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តត្បូងឃ្មុំ |
| ៧២. **លោកស្រី ហ៊ី សុខហាន** | មន្ត្រីការិយាល័យនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តត្បូងឃ្មុំ |

# ជំពូក ១

# ព័ត៌មានទូទៅ

## ១.១ សេចក្តីផ្តើម

នៅឆ្នាំ២០២៣ វិស័យកសិកម្មកម្ពុជាបានចូលរួមចំណែកដ៏ធំធេងដល់ផលិតផលក្នុងស្រុកសរុប (ផ.ផ.ស) ប្រមាណ២២,១% (គិតជាតម្លៃបច្ចុប្បន្ន) ក្នុងនោះ ផ្នែកដំណាំ (៥៧,១%) ផ្នែកជលផល(២៤,៨%) ផ្នែកផលិតកម្មសត្វ (១១,២%) និងផ្នែកព្រៃឈើ(៧,០%)។ ក្នុងបរិបទនេះ ការផលិតផែនទីដំណាំពិតជាមានសារៈសំខាន់ណាស់ដើម្បីវាយតម្លៃ និងតាមដានឱ្យបានត្រឹមត្រូវពីការប្រើប្រាស់ដីកសិកម្ម និងសុខភាពដីកសិកម្ម ដោយជួយផ្តល់ព័ត៌មានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តក្នុងការអភិវឌ្ឍន៍វិស័យកសិកម្មប្រកបដោយនិរន្តរភាព និងការកែលម្អផលិតភាពក្នុងវិស័យកសិកម្មកម្ពុជា។

ការវាយតម្លៃនិងតាមដានការប្រើប្រាស់ដីកសិកម្ម និងសុខភាពដីកសិកម្ម ពិតជាមានសារៈសំខាន់ណាស់ក្នុងការបង្ហាញពីភាពខុសគ្នារវាងដំណាំរយៈពេលខ្លី និងដំណាំអចិន្ត្រៃយ៍។ ដំណាំរយៈពេលខ្លី ជាដំណាំដែលមានវដ្តនៃការដាំដុះរយៈពេលតិចជាងមួយដងក្នុងមួយឆ្នាំ បន្ទាប់ពីប្រមូលផលដំណាំទាំងនោះត្រូវបានដាំដុះជាថ្មី។ ដំណាំរយៈពេលខ្លី មានប្រភេទដំណាំសំខាន់ៗចំនួន១៤មុខ ដូចជាដំណាំធញ្ញជាតិ និងដំណាំយកគ្រាប់ ដំណាំពពួកសណ្តែក ដំណាំធញ្ញជាតិយកប្រេង និងបន្លែជាច្រើនប្រភេទផ្សេងទៀត។ ម៉្យាងវិញទៀត ដំណាំអចិន្ត្រៃយ៍ ជាដំណាំមានវដ្តនៃការដាំដុះរយៈពេលយូរជាងមួយឆ្នាំ។ ដំណាំសំខាន់ៗចំនួន១១មុខត្រូវបានកំណត់ជាដំណាំអចិន្ត្រៃយ៍ រួមមាន ដំណាំហូបផ្លែ ដំណាំយកគ្រាប់ ដំណាំយកប្រេង និងដំណាំគ្រឿងទេស និងដំណាំជាច្រើនប្រភេទផ្សេងទៀត។

ជាក់ស្តែង ដំណាំស្វាយចន្ទី មៀនប៉ៃលិន ស្វាយ ដូង ស្រកានាគ ម្រេច ទុរេន ជាដើម ត្រូវបានចាត់ចូលជាដំណាំអាទិភាពសម្រាប់ការងារផលិតផែនទីដំណាំ ដើម្បីជួយលើកកម្ពស់កម្មវិធីអភិវឌ្ឍន៍ខ្សែច្រវាក់តម្លៃដំណាំដែលអនុវត្ត ដោយអគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ការកំណត់អាទិភាពមុខដំណាំនេះ គឺអាស្រ័យលើស្ថានភាពភូមិសាស្ត្រនិងតំបន់ដាំដុះដំណាំជាក់ស្តែងនៅក្នុងប្រទេស។

ការផលិតផែនទីគម្របដី និងផែនទីដំណាំ គឺផ្តល់សារៈប្រយោជន៍យ៉ាងធំធេងក្នុងការប្រើប្រាស់ទិន្នន័យផ្កាយរណប។ ព័ត៌មានផ្កាយរណប ផ្តល់នូវទិន្នន័យសំខាន់ៗ ទៅលើផ្ទៃភពផែនដីដែលជួយឱ្យការផលិតផែនទីមានកម្រិតជឿជាក់ខ្ពស់ និងមានសមត្ថភាពដឹងពីបាតុភូតផ្សេងៗ។ ព័ត៌មានភូមិសាស្ត្រដែលទទួលបានពីព័ត៌មានផ្កាយរណបដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហាពាក់ព័ន្ធនៅក្នុងតំបន់ត្រូពិក រួមមានការកាប់បំផ្លាញព្រៃឈើ ការប៉ាន់ប្រមាណជីវម៉ាសការបាត់បង់ជីវចម្រុះ គ្រោះរាំងស្ងួត និងផលប៉ះពាល់លើសហគមន៍ជនបទ ដីធ្លី ការដុះលូតលាស់រុក្ខជាតិ សត្វព្រៃ ទីជម្រាល និងនិន្នាការអាកាសធាតុសកល។ កម្មវិធីចម្បងនៃព័ត៌មានផ្កាយរណប គឺការផលិតផែនទីប្រើប្រាស់ដី/គម្របដី ដែលបង្ហាញពីការប្រើប្រាស់ដីដែលកើតចេញពីសកម្មភាពផ្សេងៗរបស់មនុស្ស ឬលក្ខណៈរូបសាស្ត្រផ្សេងៗទៀតនៅលើផែនដី។

ម៉ាស៊ីនស្វ័យសិក្សា បានក្លាយជាវិធីសាស្ត្រសម្រាប់ផលិតផែនទីគម្របដី ដោយបានផ្លាស់ប្តូរពីវិធីសាស្ត្រផលិតផែនទីតាមទម្លាប់។ ជាពិសេសម៉ូដែល CNNs ដែលជាសំណុំមួយនៃការសិក្សាស៊ីជម្រៅ និងស្ថិតនៅក្នុងផ្នែកនៃបញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផលិតផែនទីដំណាំ។ រូបមន្តដោះស្រាយលើម៉ាស៊ីនស្វ័យសិក្សាមានសមត្ថភាពខ្ពស់ក្នុងការកំណត់គំរូនៅក្នុងទិន្នន័យភូមិសាស្ត្ររួមមានស្ថានភាពដីនិងលក្ខណៈបរិស្ថាន គំរូថ្មីៗនិងទំនើប ជាច្រើនទៀត គឺត្រូវបានប្រើសម្រាប់ធ្វើចំណាត់ថ្នាក់គម្របដី ដូចជាប្រភេទដំណាំជាដើម។ ម៉ូដែលបណ្តាញណឺរ៉ូន រួមមាន CNNs មានសមត្ថភាពមិនត្រឹមតែវិភាគពណ៌នៃផ្ទៃក្រឡា (pixel) ប៉ុណ្ណោះទេ ថែមទាំងអាចវិភាគព័ត៌មានដ៏ស្មុគស្មាញជាច្រើនទៀតដូចជាលក្ខណៈរបស់រូបភាពនិងការផ្គុំរូបភាពជាច្រើន ដើម្បីបង្កើតផែនទីដំណាំឱ្យបានត្រឹមត្រូវ។ សមត្ថភាពក្នុងការផលិតផែនទីនេះ មានផលប្រយោជន៍យ៉ាងខ្លាំងសម្រាប់ការរៀបចំគោលនយោបាយ ដោយជួយផ្តល់ជាព័ត៌មានក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងវិស័យផ្សេងៗដូចជា កសិកម្ម នគរូបនីយកម្ម ការគ្រប់គ្រងគ្រោះមហន្តរាយ និងការតាមដានត្រួតពិនិត្យបរិស្ថាន។ វិធីសាស្ត្រផលិតផែនទីបែបបុរាណកំពុងត្រូវបានពង្រឹងបន្ថែម ឬត្រូវបានជំនួស ដោយប្រព័ន្ធបញ្ញា ឆ្លាតវៃនេះបង្ហាញថាបច្ចេកវិទ្យាទំនើបមានតួនាទីយ៉ាងសំខាន់ក្នុងការផលិតផែនទីព័ត៌មានភូមិសាស្ត្រ។

ការប្រើប្រាស់ម៉ូដែល CNNs ក្នុងការផលិតផែនទីដំណាំ ជាពិសេសសម្រាប់ដំណាំស្វាយចន្ទី បានក្លាយជាកម្មវិធីផ្លាស់ប្តូរមួយនៅក្នុងវិស័យកសិកម្ម។ CNNs គឺជាសំណុំមួយនៃគំរូការសិក្សាស៊ីជម្រៅ ដែលត្រូវបានបង្កើតឡើងសម្រាប់ធ្វើការវិភាគរូបភាព និងសម្គាល់រូបភាព ដែលពិតជាស័ក្តិសមសម្រាប់ការងារដែលពាក់ព័ន្ធនឹងរូបភាពផ្កាយរណប ឬ រូបភាពពីលើអាកាស។ នៅក្នុងបរិបទនៃការផលិតផែនទីស្វាយចន្ទី ម៉ូដែល CNNs មានសមត្ថភាពក្នុងការធ្វើស្វ័យប្រវត្តិកម្មក្នុងការកំណត់អត្តសញ្ញាណ និងចំណាត់ថ្នាក់នៃលក្ខណៈពិសេសដែលមានក្នុងរូបភាព ដោយជួយឱ្យដំណើរការផលិតផែនទីនេះកាន់តែមានប្រសិទ្ធភាព និងមានភាពត្រឹមត្រូវ។ រូបភាពពីផ្កាយរណបផ្តល់នូវព័ត៌មានជាច្រើនអំពីផ្ទៃផែនដី ហើយម៉ូដែល CNNs អាចវិភាគទិន្នន័យទាំងនោះប្រកបដោយប្រសិទ្ធភាពក្នុងកំណត់លក្ខណៈផ្សេងៗនៃដំណាំស្វាយចន្ទី។ ម៉ូដែលនេះសិក្សាសម្គាល់ពីលក្ខណៈនៃដើមស្វាយចន្ទី ដូចជារូបរាងដើមស្វាយចន្ទី ទំហំ និងការដុះលូតលាស់ ដែលជាចំណុចសម្រាប់កំណត់អត្តសញ្ញាណស្វាយចន្ទី។ ម៉ូដែល CNNs មានសមត្ថភាពក្នុងការទាញយកលក្ខណៈពិសេសនៃរូបភាពតាមលំដាប់លំដោយ ដោយរួមចំណែកយ៉ាងសំខាន់ក្នុងការដោះស្រាយការប្រែប្រួលសណ្ឋានដី អាកាសធាតុ និងការ អនុវត្តការដាំដុះ។ លើសពីនេះ ម៉ូដែល CNNs ក្នុងការផលិតផែនទីស្វាយចន្ទីជួយសម្រួលដល់ការផលិតផែនទីបានលម្អិត និងទាន់បច្ចុប្បន្នភាព ដែលផ្តល់ជាព័ត៌មានដ៏មានតម្លៃសម្រាប់កសិករ អ្នកគ្រប់គ្រងដីធ្លី និងអ្នកតាក់តែងគោលនយោបាយ។

បច្ចេកវិទ្យានេះមិនត្រឹមតែអាចកំណត់អត្តសញ្ញាណដំណាំស្វាយចន្ទីប៉ុណ្ណោះទេថែមទាំងអាចតាមដានសុខភាព និងការលូតលាស់របស់ដំណាំទៀតផង។ ទិន្នន័យនៃពេលវេលាជាក់ស្តែងពីការផលិតផែនទីដំណាំពីម៉ូដែល CNNs អាចជួយដល់ការបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តកសិកម្ម ការបែងចែកធនធាន ការធ្វើសេចក្តីសម្រេចចិត្ត ហើយក៏រួមចំណែកដល់ការបង្កើនទិន្នផល និងការដាំដុះដំណាំស្វាយចន្ទីប្រកបដោយនិរន្តរភាពផងដែរ។

## ១.២ គោលបំណង

គោលបំណងសំខាន់នៃការផលិតផែនទី គឺផ្តល់ព័ត៌មានជាក់លាក់អំពីគម្របដំណាំនៅទូទាំងប្រទេសកម្ពុជាដើម្បីរួមចំណែកក្នុងការរៀបចំគោលនយោបាយ ការអភិវឌ្ឍន៍ផែនការ និងផែនការយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងធនធានកសិកម្មរបស់ប្រទេសកម្ពុជា។ ការផលិតផែនទីនេះមានគោលបំណងសំខាន់ៗចំនួន០៤ គឺ៖

- ដើម្បីធ្វើបច្ចុប្បន្នភាព និងផលិតផែនទីសម្រាប់ដំណាំដែលមានសក្តានុពលខ្ពស់ដូចជា ដំណាំស្វាយចន្ទី ស្វាយ ដូង ទុរេន មៀនប៉ៃលិន ដំឡូងមី ពោត ចេក អំពៅ និងម្រេច។
- ដើម្បីផ្តល់ព័ត៌មានសំខាន់ៗក្នុងការតាមដានការផ្លាស់ប្តូរមុខដំណាំកសិកម្ម និងជួយសម្រួលដល់ការធ្វើផែនការយុទ្ធសាស្ត្រដើម្បីបង្កើនផលិតកម្មកសិកម្មសម្រាប់ការនាំចេញ។
- ដើម្បីធ្វើទំនើបកម្មវិធីសាស្ត្រផលិតផែនទីដំណាំ ដោយផ្លាស់ប្តូរពីគូសវាសដោយដៃ ទៅការប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត និងម៉ាស៊ីនស្វ័យសិក្សា។
- ដើម្បីគាំទ្រដល់ការផលិតផែនទីតំបន់ដំណាំសម្រាប់ជាជំនួយក្នុងការៀបចំផែនការកសិកម្ម និងការគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាព។

## ១.៣ លទ្ធផលរំពឹងទុក

- ផលិតផែនទីដំណាំស្វាយចន្ទីដែលមានកម្រិតជឿជាក់ខ្ពស់សម្រាប់ប្រទេសកម្ពុជា
- បង្កើតស្តង់ដារនៃការប្រមូលទិន្នន័យ ទិន្នន័យយោង និងម៉ូដែល សម្រាប់យកទៅអនុវត្តក្នុងការផលិតផែនទីដំណាំកសិកម្មដែលមានសក្តានុពលខ្ពស់ដូចជា ដំណាំស្វាយ ដូង ទុរេន មៀនប៉ៃលិន ដំឡូងមី ពោត ចេក អំពៅ និងម្រេចជាដើម។

## ១.៤ ភាពសមស្របនៃដីសម្រាប់ដំណាំស្វាយចន្ទីនៅកម្ពុជា

ភាពសមស្របនៃដីសម្រាប់ដំណាំស្វាយចន្ទីនៅទូទាំងប្រទេសកម្ពុជា ត្រូវបានបែងចែកជា៥ចំណាត់ថ្នាក់ ក្នុងនោះមាន (១) សមស្របខ្ពស់ មានចំនួន ១ ២៤៣ ៥៨១ ហិកតា (២) សមស្រប មានចំនួន ៥ ០៩៧ ៣៩៦ ហិកតា (៣) សមស្របមធ្យម មានចំនួន៦ ៧៨៥ ៧២៦ ហិកតា (៤) សមស្របទាប មានចំនួន ៣ ៨១៥ ៦៥២ ហិកតា និង (៥) មិនសមស្រប មានចំនួន ៧២៦ ៣៩៩ ហិកតា។ ផ្អែកតាមការវាយតម្លៃនេះ ប្រទេសកម្ពុជាមានផ្ទៃដីប្រមាណ ១,២៤លានហិកតា ដែលមានភាពសម្របបំផុតសម្រាប់ដាំដុះដំណាំស្វាយចន្ទី និងផ្ទៃដីប្រមាណ ៥លានហិកតា មានភាពសមស្របដែលត្រូវការប្រើប្រាស់ធាតុចូលកសិកម្មតិចតួចដើម្បីរក្សានិរន្តភាពផលិតកម្ម។




## ការពិពណ៌នាចំណាត់ថ្នាក់ភាពសមស្របនៃដីសម្រាប់ផលិតកម្មដំណាំកសិកម្ម

| ចំណាត់ថ្នាក់ភាពសមស្រប | ការពិពណ៌នា |
|---|---|
| S1, សមស្របខ្ពស់ | ដីដែលមានលក្ខណៈសមស្របសម្រាប់ធានានិរន្តរភាពផលិតកម្មដំណាំ ដោយមិនចាំបាច់ធ្វើការកែលម្អ។ |
| S2, សមស្រប | ដីដែលមានលក្ខណៈសមស្របសម្រាប់ធានានិរន្តរភាពផលិតកម្មដំណាំ និងអាចមានការកែលម្អបញ្ហាប្រឈមតិចតួច ប៉ុន្តែមិនបង្កើនធាតុចូលកសិកម្មខ្ពស់ហួសពីកម្រិតដែលអាចទទួលយកបាន។ |
| S3, សមស្របមធ្យម | ដីដែលមានបញ្ហាប្រឈមច្រើន ដោយទាមទារឱ្យមានការកែលម្អ និងបង្កើនធាតុចូលកសិកម្មដែលចាំបាច់ ដើម្បីទទួលបានផលប្រយោជន៍ពីផលិតកម្មដំណាំ ។ |
| N1, សមស្របទាប | ដីដែលមានបញ្ហាប្រឈមធ្ងន់ធ្ងរសម្រាប់ផលិតកម្មដំណាំ ហើយការប្រើប្រាស់ដីត្រូវពិចារណាឱ្យបានល្អិតល្អន់ ប៉ុន្តែមិនធានាថាផ្តល់នូវតម្លៃសេដ្ឋកិច្ច និងសង្គមឡើយ។ |
| N2, មិនសមស្រប | ដីដែលមានបញ្ហាប្រឈមធ្ងន់ធ្ងរសម្រាប់ផលិតកម្មដំណាំ ហើយការប្រើប្រាស់ដីត្រូវពិចារណាឱ្យបានល្អិតល្អន់ ប៉ុន្តែមិនធានាថាផ្តល់នូវតម្លៃសេដ្ឋកិច្ច និងសង្គមឡើយ។ |

# ជំពូក ២

# វិធីសាស្ត្រផលិតផែនទីដំណាំ

## ២.១ បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI) ម៉ាស៊ីនស្វ័យសិក្សា (ML) និង ការសិក្សាស៊ីជម្រៅ (DL)

បញ្ញាសិប្បនិម្មិតគឺជាកម្មវិធីនៃការបង្កើតម៉ាស៊ីនដែលមានសមត្ថភាពបំពេញការងារដែលជាធម្មតាត្រូវការភាពឆ្លាតវៃរបស់មនុស្ស ដូចជា ការសម្រេចចិត្តនិងការយល់ដឹងអំពីភាសា។ ម៉ាស៊ីនស្វ័យសិក្សា គឺជាផ្នែកមួយនៃបញ្ញាសិប្បនិម្មិតដែលវាសិក្សាពីទិន្នន័យដើម្បីបង្កើនប្រសិទ្ធភាពការងារលើកិច្ចការជាក់លាក់ណាមួយ ដោយមិនចាំបាច់មានកម្មវិធីច្បាស់លាស់។ ការសិក្សាស៊ីជម្រៅ គឺជាផ្នែកមួយទៀតនៃម៉ាស៊ីនស្វ័យសិក្សា ដែលប្រើប្រាស់បណ្តាញណឺរ៉ូនដែលមានច្រើនស្រទាប់ដើម្បីវិភាគលើលំនាំដ៏ស្មុគស្មាញនៅក្នុងសំណុំទិន្នន័យធំៗ។ បច្ចេកវិទ្យាទាំងនេះមានអត្ថប្រយោជន៍ណាស់ ជាពិសេសក្នុងការងារផលិតផែនទីសម្រាប់វិស័យកសិកម្ម ដូចជាការផលិតផែនទីដំណាំ ព្រោះអាចដំណើរការជាមួយរូបភាពផ្កាយរណបនិងទិន្នន័យផ្សេងទៀតយ៉ាងមានប្រសិទ្ធភាពដើម្បីកំណត់និងតាមដានប្រភេទដំណាំផ្សេងៗបានយ៉ាងមានប្រសិទ្ធភាព។ ឧទាហរណ៍ ម៉ូដែលសិក្សាស៊ីជម្រៅអាចបែងចែករវាងដំណាំស្វាយចន្ទី និងដំណាំផ្សេងទៀតបាន ដោយប្រើរូបភាពផ្កាយរណបដែលមានភាពជាក់លាក់ខ្ពស់ ជួយដល់ការគ្រប់គ្រងធនធាន និងការព្យាករណ៍ទិន្នផលបានកាន់តែល្អប្រសើរ (Zhao et al., 2021)។

## ២.២ បណ្តាយណឺរ៉ូន (NN)

បណ្តាញណឺរ៉ូនគឺជាម៉ូដែលគណនាមួយដែលត្រូវបានអនុវត្តឱ្យដូចទៅនឹងបណ្តាញសរសៃប្រសាទជីវសាស្ត្រនៅក្នុងដំណើរការព័ត៌មានខួរក្បាលរបស់មនុស្ស។ វាមានស្រទាប់ដែលតភ្ជាប់គ្នាពីមួយទៅមួយទៀតដែលហៅថាណឺរ៉ូន (neurons)ដែលធ្វើការរួមគ្នាដើម្បីស្គាល់នូវលក្ខណៈសម្បត្តិ ធ្វើការសម្រេចចិត្ត និងរៀនពីទិន្នន័យផ្សេងៗ។ បណ្តាញណឺរ៉ូនត្រូវបានប្រើនៅក្នុងកម្មវិធីផ្សេងៗ រួមមានការបកប្រែរូបភាព បកប្រែភាសាជាអក្សរ និងជាសំលេង ។ល។ បណ្តាញណឺរ៉ូនមានច្រើនប្រភេទសម្រាប់ប្រើប្រាស់លើកិច្ចការងារផ្សេងៗគ្នាដូចខាងក្រោម៖

- បណ្តាញណឺរ៉ូន **Feedforward** (**FNNs**)៖ ជាប្រភេទសាមញ្ញបំផុតដែលព័ត៌មានផ្លាស់ទីក្នុងទិសដៅមួយពី input nodes ទៅ hidden nodes បន្ទាប់មកចេញទៅ output nodes ។
- បណ្តាញណឺរ៉ូន **Recurrent** (**RNNs**)៖ បណ្តាញទាំងនេះមានការតភ្ជាប់គ្នា ដែលបង្កើតជាវដ្តរង្វង់ដែលអនុញ្ញាតឱ្យរក្សាទុកព័ត៌មាននៅក្នុងអង្គចងចាំបាន។ **RNNs** មានសារៈសំខាន់ក្នុងការរក្សាទិន្នន័យបន្តបន្ទាប់គ្នាដូចជាព័ត៌មានTime series ឬព័ត៌មានអត្ថបទជាដើម។
- បណ្តាញណឺរ៉ូន **Convolutional** (**CNNs**)៖ ប្រើប្រាស់សម្រាប់ដំណើរការបង្កើតរចនាសម្ព័ន្ធទិន្នន័យដូចទៅនឹងក្រឡាចត្រង្គរួមមានរូបភាពជាដើម។ **CNNs** ប្រើស្រទាប់ convolutional ដើម្បីរកមើលលក្ខណៈពិសេស។

- បណ្ដាញណឺរ៉ូន **Generative Adversarial Networks** ( **GANs** ) ៖ រួមបញ្ចូលគ្នារវាងពីរបណ្ដាញគឺ Generator and Discriminator ធ្វើការរួមគ្នាដើម្បីបង្កើតទិន្នន័យជាក់ស្ដែង ហើយក៏មានសារៈសំខាន់ក្នុងការបង្កើតរូបភាព និងកិច្ចការច្នៃប្រឌិតផ្សេងទៀត។
- **Autoencoders** ៖ ប្រើសម្រាប់ការរៀនដោយខ្លួនឯងឬរៀនដោយគ្មានទិន្នន័យបង្ហាត់ បណ្ដាញទាំងនេះបំប្លែងទិន្នន័យជាភាសាកុំព្យូទ័ររួចបញ្ចូលទៅក្នុងទម្រង់សាមញ្ញមួយ ហើយបន្ទាប់មក Decode មកវិញ។ មានប្រយោជន៍សម្រាប់កិច្ចការដូចជាការកាត់បន្ថយសំឡេងរំខាន និងការរៀនពីលក្ខណៈសម្បត្តិជាដើម។

សម្រាប់ការងារក្នុងការផលិតផែនទីស្វាយចន្ទី បណ្ដាញណឺរ៉ូន( CNNs ) គឺជាជម្រើសដ៏ល្អបំផុតមួយព្រោះត្រូវបានរចនាឡើងសម្រាប់ដំណើរការទិន្នន័យដូចក្រឡាចត្រង្គដែលមានទម្រង់ដូចជារូបភាព។ បណ្ដាញណឺរ៉ូនCNNs ប្រើប្រាស់ស្រទាប់ Convolutional ដើម្បីរៀនពីឋានានុក្រមនៃលក្ខណៈពិសេសរបស់រូបភាពក្នុងកម្រិតមាត្រដ្ឋានខុសគ្នាក្នុងការយកទៅប្រើប្រាស់។ CNNs មានប្រសិទ្ធភាពខ្ពស់សម្រាប់កិច្ចការដែលពាក់ព័ន្ធនឹងការចាត់ថ្នាក់រូបភាព ការកំណត់សម្គាល់វត្ថុ និងការបែងចែករូបភាពជាដើម។ បណ្ដាញណឺរ៉ូន CNNs មានសារៈសំខាន់សម្រាប់ការធ្វើផែនទីដំណាំ ដោយមានសមត្ថភាពដូចខាងក្រោម៖

- ទាញយកលក្ខណៈពិសេសពីលម្ហ ( **Spatial Features** )៖ វាអាចកំណត់អត្តសញ្ញាណ និងសិក្សាពីលក្ខណៈសំខាន់ៗពីក្នុងរូបភាពផ្កាយរណប ឬពីលើអាកាស ដូចជាប្រភេទដំណាំ ស្ថានភាពដី និងសុខភាពរុក្ខជាតិ ឬដំណាំជាដើម។
- លទ្ធភាពក្នុងការប្រើប្រាស់លើទិន្នន័យធំៗ៖ CNNs អាចដំណើរការ និងវិភាគយ៉ាងមានប្រសិទ្ធភាពនូវសំណុំទិន្នន័យធំនៃរូបភាពដែលមានគុណភាពបង្ហាញខ្ពស់។
- ធ្វើឱ្យប្រសើរឡើងនូវភាពច្បាស់លាស់នៃផែនទី៖ អាចកំណត់ និងចាត់ថ្នាក់ប្រភេទដំណាំផ្សេងៗបានយ៉ាងមានប្រសិទ្ធភាព ។ CNNs បង្កើនភាពជាក់លាក់ក្នុងការរៀបចំផែនទីដំណាំដែលនាំឱ្យការគ្រប់គ្រង និងការធ្វើផែនការកសិកម្មឱ្យកាន់តែប្រសើរឡើង។

## ២.៣ The Google cloud environment

### ២.៣.១ ដំណើរការអនុវត្ត

បន្ទាប់ពីជ្រើសរើសបច្ចេកវិទ្យាសមស្របដូចជាការសិក្សាស៊ីជម្រៅរួមបញ្ចូលគ្នាជាមួយម៉ូដែលCNNs សម្រាប់ធ្វើការបង្ហាត់បង្រៀនដើម្បីផលិតផែនទីដំណាំជាពិសេសផែនទីស្វាយចន្ទី កម្មវិធីមួយចំនួនដូចជា Google Earth Engine និង Google Cloud Environment ដើរតួនាទីយ៉ាងសំខាន់។ កម្មវិធីទាំងនេះគឺជាហេដ្ឋារចនាសម្ព័ន្ធចាំបាច់សម្រាប់ធ្វើជាទីកន្លែងផ្ទុកទិន្នន័យនិងបង្ហាត់បង្រៀនម៉ូដែល ផ្ដល់នូវធនធានកុំព្យូទ័រក្នុងការកម្រិតមាត្រដ្ឋានផ្សេងៗគ្នា និងអាចទាញយករូបភាពផ្កាយរណបជាច្រើនដើម្បីប្រើប្រាស់។ ការរួមបញ្ចូលគ្នានៃកម្មវិធីទាំងនេះ ជួយឱ្យដំណើរការ និងការវិភាគកាន់

តែមានប្រសិទ្ធភាពដែលនាំឱ្យការផលិតផែនទីដំណាំមានភាពត្រឹមត្រូវ និងភាពជឿជាក់ខ្ពស់។ ឧទាហរណ៍ ការប្រើ Google Earth Engine ជួយឱ្យអ្នកស្រាវជ្រាវអាចទាញយកនិងវិភាគទិន្នន័យចាស់ៗ ឬទិន្នន័យរូបភាពផ្កាយរណបតាមពេលវេលាជាក់ស្តែងណាមួយ ខណៈដែល Google Cloud ផ្តល់លទ្ធភាពក្នុងការគណនា និងដោះស្រាយរាល់សំណុំទិន្នន័យធំៗព្រមទាំងម៉ូដែលដ៏ស្មុគស្មាញជាច្រើនទៀត វាក៏អាចជួយបង្កើនភាពជឿជាក់ និងប្រសិទ្ធភាពខ្ពស់ក្នុងការផលិតផែនទីដំណាំបានផងដែរ (Kamilaris & Prenafeta -Boldú, ២០១៨)។ ទិន្នន័យបង្ហាត់ដូចជារូបភាពផ្កាយរណប និងទិន្នន័យទីវាលផ្សេងៗទៀត ត្រូវបានដាក់បញ្ចូលក្នុងកម្មវិធី Google Earth Engine។ ទិន្នន័យដែលផលិតបានត្រូវបានរក្សាទុកជា TensorFlow Record នៅក្នុង Google Cloud។ បន្ទាប់មកយើងប្រើប្រាស់ AI Platform នៅក្នុង Google Colab ដើម្បីដំណើរការកូដ ហើយប្រើប្រាស់ TensorFlow ជាកន្លែងផ្ទុកទិន្នន័យសម្រាប់បង្កើតបណ្តាញណឺរ៉ូនដើម្បីផលិតជាម៉ូដែល។ ជាចុងក្រោយយើងបានផ្ទេរលទ្ធផល ឬផែនទីចុងក្រោយត្រឡប់ទៅកម្មវិធី Google Earth Engine វិញសម្រាប់មើលផែនទីលម្អិត និងផ្ទៀងផ្ទាត់ (រូបភាពទី១)។



រូបភាពទី១: ការប្រើប្រាស់ Google Cloud Environment សម្រាប់ដំណើរនិងវិភាគរូបភាពផ្កាយរណប

## ២.៤ ការរៀបចំទិន្នន័យបង្ហាត់

ការជ្រើសរើសបច្ចេកវិទ្យា និងម៉ូដែលបានត្រឹមត្រូវពិតជាមានសារៈសំខាន់ណាស់សម្រាប់ការផលិតផែនទីដំណាំ ប៉ុន្តែអ្វីដែលសំខាន់មិនអាចខ្វះបានគឺទិន្នន័យបង្ហាត់ដើម្បីផលិតបានផែនទីដែលមានកម្រិតជឿជាក់ខ្ពស់។ ទិន្នន័យបង្ហាត់គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ប្រើប្រាស់ក្នុងម៉ូដែល CNNs ដើម្បីផលិតផែនទីដំណាំ។ ទិន្នន័យដែលត្រូវយកទៅប្រើប្រាស់ក្នុងម៉ូដែលទាមទារឱ្យមានព័ត៌មានយ៉ាងលម្អិតពីចំណាត់ថ្នាក់ប្រភេទដំណាំផ្សេងៗ ដោយរួមបញ្ចូលនូវព័ត៌មានមួយចំនួនទៀតដូចជា៖ កាលបរិច្ឆេទ (ពេលវេលាចុះទីវាល និងរូបភាពផ្កាយរណប) ព័ត៌មានទីវាល ព័ត៌មានការប្រើប្រាស់ដី និងគម្របដី។ នៅក្នុងម៉ូដែល ទិន្នន័យបង្ហាត់ត្រូវតែមានទ្រង់ទ្រាយជាប៉ូលីហ្គោនក្នុងប្លង់ទំហំ ៤x៤គ.ម ហើយប៉ូលីហ្គោននោះត្រូវមានព័ត៌មានលម្អិតពីការប្រើប្រាស់ដី (រូបភាពទី២)។



រូបភាពទី២: ការរៀបចំទិន្នន័យបង្ហាត់

### ២.៤.១ ការជ្រើសរើសតំបន់គោលដៅ

ខេត្តចំនួន១៩ ក្នុងប្រទេសកម្ពុជា ត្រូវបានជ្រើសរើសក្នុងការចុះប្រមូលទិន្នន័យដើម្បីជាមូលដ្ឋានគ្រឹះក្នុងការផលិតផែនទីដំណាំស្វាយចន្ទី រួមមានខេត្តៈ ខេត្តត្បូងឃ្មុំ ប៉ៃលិន ឧត្តរមានជ័យ ស្ទឹងត្រែង ព្រះសីហនុ សៀមរាប រតនគីរី ពោធិ៍សាត់ ព្រះវិហារ មណ្ឌលគិរី ក្រចេះ កោះកុង កំពត កំពង់ធំ កំពង់ស្ពឺ កំពង់ឆ្នាំង កំពង់ចាម បាត់ដំបង និងបន្ទាយមានជ័យ ត្រូវបានជ្រើសរើសយ៉ាងល្អិតល្អន់សម្រាប់ការធ្វើផែនទីតំបន់ដាំដុះដំណាំស្វាយចន្ទី។ ការជ្រើសរើសខេត្តគោលដៅទាំងនោះទាមទារឱ្យពិនិត្យ និងពិភាក្សាយ៉ាងល្អិតល្អន់ដើម្បីធានាបានថាខេត្តគោលដៅនិងតំបន់ដែលបានជ្រើសរើសទាំងនោះមានព័ត៌មានគ្រប់គ្រាន់ពីតំបន់ដាំដុះដំណាំស្វាយចន្ទី ព្រោះវាជាមូលដ្ឋានគ្រឹះក្នុងការប្រមូលទិន្នន័យសម្រាប់ធ្វើការវិភាគ (រូបភាពទី៣)។



រូបភាពទី៣: ខេត្តគោលដៅទាំង១៩

### ២.៤.២ ការរៀបចំប្លង់យកទិន្នន័យ

បន្ទាប់ពីបានជ្រើសរើសខេត្តគោលដៅរួចរាល់ហើយ ដំណាក់ការបន្ទាប់គឺជ្រើសរើសនិងកំណត់ទីតាំងប្រមូលទិន្នន័យ ក្រុមការងារបានបង្កើតប្លង់ទំហំ ៤x៤គ.ម ក្នុងខេត្តគោលដៅនីមួយៗ ដើម្បីប្រាកដថាប្លង់ទាំងនោះតំណាងឱ្យការប្រើប្រាស់ដីក្នុងខេត្តគោលដៅទាំងនោះ ហើយក្នុងបង្កើតប្លង់ត្រូវបានប្រើប្រាស់កម្មវិធីព័ត៌មានភូមិសាស្ត្រ ArcGIS/QGIS។ ឧទាហរណ៍ ក្នុងការប្រមូលទិន្នន័យក្នុងខេត្តកំពង់ធំ ប្លង់ទាំងនោះត្រូវមានព័ត៌មានពីការប្រើប្រាស់ដីយ៉ាងលម្អិត គឺមិនត្រឹមតែប្រមូលព័ត៌មានតែដំណាំស្វាយចន្ទីមួយមុខទេ។ ជាទូទៅក្នុងការជ្រើសរើសប្លង់ទំហំ ៤x៤គ.ម សម្រាប់ខេត្តគោលដៅនីមួយៗ គឺមានចំនួនច្រើនជាង ១០ ប្លង់ ដើម្បីធានាបានថាទិន្នន័យដែលប្រមូលបានគឺគ្រប់ដណ្តប់បានល្អ។ លើសពីនេះផ្លូវហោះហើររបស់ដ្រូនត្រូវបានបង្កើតឡើងនៅលើប្លង់ទាំងនោះ ដើម្បីជួយសម្រួលដល់ដំណើរការប្រមូលទិន្នន័យប្រកបដោយប្រសិទ្ធភាព (រូបភាពទី៤)។




រូបភាពទី៤: ការរៀបចំប្លង់យកទិន្នន័យក្នុងកម្មវិធី QGIS

## ២.៤.៣ ការងារទីវាល

ការប្រមូលទិន្នន័យនៅទីវាលក្រុមការងារត្រូវបានបែងចែកជាពីរក្រុម ដើម្បីអនុវត្តការងារប្រមូលទិន្នន័យប្រកបដោយប្រសិទ្ធភាព។ ក្រុមទីមួយមានភារកិច្ចរៀបចំនិងបង្ហោះដ្រូន ដើម្បីចាប់យករូបភាពលើអាកាសក្នុងប្លង់ទំហំ ៤x៤គ.ម ទាំងមូល។ ទន្ទឹមនឹងនេះ ក្រុមទីពីរបានប្រើប្រាស់កម្មវិធី CarryMap នៅលើទូរស័ព្ទឬថេប្លេត ដើម្បីធ្វើការកំណត់ចំណុច កូអរដោនេ និងគូសជាប៉ូលីហ្គោន។ ចំណុច និងប៉ូលីហ្គោនទាំងនេះត្រូវបានសសេរពីព័ត៌មានស្ថានភាពទូទៅ។ ក្រុមការងារក៏បានធ្វើការកត់ត្រា និងប្រមូលព័ត៌មានសំខាន់ៗជាច្រើន ដូចបានបង្ហាញក្នុងតារាងទី១។

# តារាងទី១: តារាងប្រមូលទិន្នន័យទីវាល

តារាងប្រមូលទិន្នន័យសម្រាប់ផលិតផែនទីផលិតកម្មដំណាំកសិកម្ម

Crop Mapping Data Collection From

| | | | |
|---|---|---|---|
| | ដំណាំសាកវប្បកម្ម / Horticultural Crops | | ដំណាំឧស្សាហកម្ម / Industrial crops |

| | | | |
|---|---|---|---|
| Feature ID<br>លេខរៀង | | Date / Time<br>កាលបរិច្ឆេទ / ម៉ោង | |
| Description<br>បរិយាយ | | Class Code / លេខកូដចំណាត់ថ្នាក់ | |
| GPS Serial No | | Surveyor / អ្នកអង្កេត | |
| Waypoints No | | Weather / អាកាសធាតុ | |
| GPS Easting ( WGS84 )<br>ខាងកើត ( x ) | | Latitude ( E )<br>រយៈទទឹង | |
| GPS Easting ( WGS84 )<br>ខាងកើត ( Y ) | | Longitude ( N )<br>រយៈបណ្តោយ | |
| Camera ID ( Model ) | | Slope / កម្រិតជម្រាល | Flat / Gentle Slope / Steep<br>រាបស្មើរ / ជម្រាល / ចោទ |
| Caption Field Photos<br>ចំណងជើងរូបភាពទីវាល | | Elevation / រយៈកម្ពស់ | |
| Photo No of 4 directions<br>ចំណងជើងរូបភាពទីវាល | N:<br>E:<br>S:<br>W: |   | |

ពិពណ៌នាចំណាត់ថ្នាក់ជុំវិញទីតាំងយើងកំពុងឈរ

Description class around the points

- ជាប់ព្រំប្រទល់ខាងជើង ( ឧទាហរណ៍: ដំឡូងមី )
- ជាប់ព្រំប្រទល់ខាងកើត ( ឧទាហរណ៍: ស្រូវ )
- ជាប់ព្រំប្រទល់ខាងត្បូង ( ឧទាហរណ៍: ស្រូវ )
- ជាប់ព្រំប្រទល់ខាងលិច ( ឧទាហរណ៍: ពោត )




Important information ( land use situation and historical of the land use change )

ព័ត៌មានចាំបាច់ ( ស្ថានភាពបច្ចុប្បន្ន ប្រវត្តិការវិវឌ្ឍនៃការប្រើប្រាស់ និងបម្រែបម្រួល )

## ២.៤.៤ ការគូសវាសទិន្នន័យបង្ហាត់

បន្ទាប់ពីបានបញ្ចប់ការប្រមូលទិន្នន័យនៅទីវាលរួច រួមមានរូបភាពថតដោយដ្រូន ចំណុចកូអរដោនេនិងប៉ូលីហ្គោន ហើយនិងព័ត៌មានពីតារាងប្រមូលទិន្នន័យសម្រាប់ផលិតផែនទីដំណាំកសិកម្ម ក្រុមការងារបានបន្តគូសវាសទិន្នន័យទាំងនោះជាប៉ូលីហ្គោនក្នុងប្លង់ទំហំ ៤x៤គ.ម ដោយរួមបញ្ចូលព័ត៌មានរូបភាពផ្កាយរណបដែលបានពីប្រភពផ្សេងៗគ្នាដូច Planet NICFI, Google Hybrid និង Bing Maps គួបផ្សំជាមួយកម្មវិធីព័ត៌មានភូមិសាស្ត្រ ArcGIS និង QGIS។ ព័ត៌មានសំខាន់ៗមួយចំនួនដូចជា៖ ឈ្មោះខេត្ត លេខសម្គាល់ប្លង់ ព័ត៌មានទីវាល អាយុកាលដំណាំ ព័ត៌មានការប្រើប្រាស់ដី ប្រភេទរូបភាពផ្កាយរណប ។ល។ វិធីសាស្ត្រនេះគឺដើម្បីធានានូវទិន្នន័យដែលមានគុណភាពខ្ពស់ក្នុងការផលិត និងផ្ទៀងផ្ទាត់ផែនទីស្វាយចន្ទី (រូបភាពទី៥)។




រូបភាពទី៥: ការគូសវាសទិន្នន័យបង្ហាត់

បន្ទាប់មកក្រុមការងារបានគូសវាសជាប៉ូលីហ្គោលក្នុងប្លង់ទាំងនោះលើខេត្តគោលទាំង១៩ខេត្ត និងបានផ្ទៀងផ្ទាត់យ៉ាងល្អិតល្អន់ នូវគុណភាពនៃការគូសវាសទិន្នន័យដែលបានបញ្ចូលរួច (ប៉ូលីហ្គោនសរុបចំនួន ៨៣ ០៣៤)។ ប៉ូលីហ្គោនចំនួ១០ ១៤៧ត្រូវបានចាត់ថ្នាក់ជាដំណាំស្វាយចន្ទី។ ទិន្នន័យដំណាំស្វាយចន្ទីត្រូវបានបែងចែកតាមអាយុកាលរបស់ដំណាំ និងការដាំដំណាំចម្រុះ ហើយទិន្នន័យដែលប្រមូលមានសរុប២១ចំណាត់ថ្នាក់ ដូចបង្ហាញក្នុងតារាងទី២ តារាងទី៣ និងរូបភាពទី៦។

តារាងទី២: ចំណាត់ថ្នាក់គម្របដី

| ល.រ | ចំណាត់ថ្នាក់ | ចំនួនប៉ូលីហ្គោន |
|---|---|---|
| ១ | ចេក | ៣១៤ |
| ២ | ដីទំនេរ | ១៣ ៩២១ |
| ៣ | ស្វាយចន្ទី | ១០ ១៤៧ |
| ៤ | ដំឡូងមី | ២ ៩៣៩២ |
| ៥ | ដូង | ២៩៥ |
| ៦ | ទុរេន | ២៤១ |
| ៧ | គម្របព្រៃ | ៧៧៦ |
| ៨ | វាលស្មៅ | ៣០ ៣៤១ |
| ៩ | ផ្ទះ | ១ ១៥៧ |
| ១០ | មៀនប៉ៃលិន | ៧២៧ |
| ១១ | ពោត | ១៧៥ |
| ១២ | ស្វាយ | ២ ៦៤៤ |
| ១៣ | ក្រូច | ១១៩ |
| ១៤ | ផ្សេងៗ | ៤៦៣ |
| ១៥ | ម្រេច | ៦៩៥ |
| ១៦ | ស្រូវ | ៣០៧ |
| ១៧ | ផ្លូវ | ៦៤៦ |
| ១៨ | កៅស៊ូ | ២ ៥១៦ |
| ១៩ | ព្រៃល្បោះ | ៦ ៧៥៤ |
| ២០ | ភូមិ | ៣ ២៩៦ |
| ២១ | ផ្ទៃទឹក | ៤ ៥៦១ |
| | **សរុប** | **៨៣ ០៣៤** |

តារាងទី៣: ចំនួនប្លង់សរុបក្នុងខេត្តគោលទាំង១៩ខេត្ត

| ល.រ | ចំណាត់ថ្នាក់ | ចំនួនប្លង់ |
|---|---|---|
| ១ | បន្ទាយមានជ័យ | ៩ |
| ២ | បាត់ដំបង | ១២ |
| ៣ | កំពង់ចាម | ១០ |
| ៤ | កំពង់ឆ្នាំង | ៨ |
| ៥ | កំពង់ស្ពឺ | ១០ |
| ៦ | កំពង់ធំ | ១៥ |
| ៧ | កំពត | ១២ |
| ៨ | កោះកុង | ៩ |
| ៩ | ក្រចេះ | ១១ |
| ១០ | មណ្ឌលគិរី | ៩ |
| ១១ | ព្រះវិហារ | ១២ |
| ១២ | ពោធិ៍សាត់ | ១០ |
| ១៣ | រតនគិរី | ១០ |
| ១៤ | សៀមរាប | ១១ |
| ១៥ | ព្រះសីហនុ | ៨ |
| ១៦ | ស្ទឹងត្រែង | ១១ |
| ១៧ | ឧត្តរមានជ័យ | ១០ |
| ១៨ | ប៉ៃលិន | ៨ |
| ១៩ | ត្បូងឃ្មុំ | ១០ |
| | **សរុប** | **១៩៥** |



រូបភាពទី៦: ទិន្នន័យគូសវាសរួចក្នុងប្លង់ ៤x៤គ.ម ក្នុងខេត្តគោលដៅចំនួន១៩

## ២.៤.៥ សម្ភារៈចុះទីវាល

ដ្រូនបានដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការប្រមូលទិន្នន័យបង្ហាត់ដើម្បីទទួលបានកម្រិតជឿជាក់ខ្ពស់។ ក្នុងដំណើរប្រមូលទិន្នន័យនៅទីវាល ក្រុមការងារបានប្រើប្រាស់ដ្រូន ៣ ប្រភេទផ្សេងៗគ្នា ដូចជា៖ Mavic 2 Pro, Mavic Air 2s និង eBee X ដើម្បីបម្រើមុខងារនិងគោលបំណងផ្សេងៗគ្នា។ ឧទាហរណ៍ Mavic 2 Pro និង Mavic Air 2s រួមជាមួយកម្មវិធី Litchi ត្រូវបានប្រើប្រាស់សម្រាប់ថតរូបភាពប្រមូលទិន្នន័យក្នុងប្លង់ទំហំ ៤x៤គ.ម ក្នុងអំឡុងពេលហោះហើរក្រុមការងារអាចធ្វើការត្រួតពិនិត្យតាមពេលវេលាជាក់ស្តែងនៃទីតាំង រយៈកម្ពស់ ល្បឿន និងកម្រិតថ្ម ដើម្បីធានាសុវត្ថិភាពនិងភាពជោគជ័យក្នុងការហោះហើរ។ eBee X ដែលបំពាក់ប្រព័ន្ធកំណត់ទីតាំងសកល (GPS) ជាមួយបច្ចេកវិទ្យា RTK/PPK សម្រាប់ការកំណត់ទីតាំងភូមិសាស្ត្រច្បាស់លាស់ រួមបញ្ចូលជាកម្មវិធី PIX4Dmapper ត្រូវបានប្រើប្រាស់សម្រាប់ផលិតផែនទីភូមិសាស្ត្រ (georeferenced base map) (រូបភាពទី៧)។




រូបភាពទី៧: ដ្រូនប្រើប្រាស់ដើម្បីប្រមូលទិន្នន័យ

## ២.៤.៦ កម្មវិធីប្រើប្រាស់

កម្មវិធីប្រព័ន្ធព័ត៌មានភូមិសាស្ត្រ ដូចជា៖ ArcGIS និង QGIS ដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការផលិតទិន្នន័យភូមិសាស្ត្រ។ កម្មវិធីទាំងនោះត្រូវបានប្រើប្រាស់សម្រាប់កំណត់តំបន់សិក្សា រៀបចំប្លង់ប្រមូលទិន្នន័យ រចនាផ្លូវរបស់ដ្រូន ការគូសវាសផែនទី(ការធ្វើបច្ចុប្បន្នភាព/ការផ្ទៀងផ្ទាត់ប្លង់) និងការត្រួតពិនិត្យប្រភពរូបភាពផ្កាយរណបផ្សេងៗដូចជា Planet NICFI, Google Hybrid និង Bing Maps ជាដើម (រូបភាពទី៨)។




រូបភាពទី៨: កម្មវិធីនិងទិន្នន័យប្រើប្រាស់

